**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល

## សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ករណីព្យាបាលជាសះស្បើយ ១៥នាក់
## និងមិនមានករណីវិជ្ជមានកូវីដ១៩ ថ្មី នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

**១. ស្ថានភាពជំងឺកូវីដ ១៩ នៅទូទាំងប្រទេស ៖**

គិតត្រឹមម៉ោង០៧:០០ព្រឹក ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ១៩ នៅកម្ពុជា មាន៖

- **អ្នកព្យាបាលជាសះស្បើយ** សរុបចំនួនកើនដល់ ៤៩នាក់ (ស្មើនឹង ៤២,៩៨% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ១៩ទាំងអស់) ដែលមានបុរសជនជាតិចិន ០១នាក់ ស្រ្តីជនជាតិអង់គ្លេស ០២នាក់ បុរសជនជាតិអង់គ្លេស ០១នាក់ បុរសជនជាតិបែលហ្សិក ០១នាក់ បុរសជនជាតិបារាំង ០៨នាក់ (ក្នុងនេះ មានទារកអាយុ ០៨ខែ) ស្រ្តីជនជាតិបារាំង ០៩នាក់ បុរសជនជាតិម៉ាឡេស៊ី ០៣នាក់ បុរសជនជាតិខ្មែរ ២៣នាក់ និងស្រ្តីជនជាតិខ្មែរ ០១នាក់ (គិតចាប់ពីខែមករាដល់បច្ចុប្បន្ននេះ)
- **អ្នកដែលកំពុងសម្រាកព្យាបាល** បានថយចុះមកនៅសរុបចំនួន **៦៥នាក់** (ស្រ្តី ២០នាក់ និងបុរស ៤៥នាក់) នៅតាមមន្ទីរពេទ្យរដ្ឋនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត
- **អ្នកមានវីរុសកូវីដ១៩ ដែលបានរកឃើញទាំងអស់** (រាប់ទាំងអ្នកដែលបានព្យាបាលជាសះស្បើយ និងអ្នកដែលកំពុងព្យាបាល) នៅទូទាំងប្រទេសសរុបចំនួន **១១៤នាក់** (ស្រ្តី ៣២នាក់ និងបុរស ៨២នាក់) ដែលចំនួននេះ មិនមានកើនទេ។

**២. ករណីជាសះស្បើយ៖** មាន ១៥នាក់

ក. បុរសអាយុ ៦៨ឆ្នាំ និងបុរសអាយុ ៦០ឆ្នាំ ជនជាតិម៉ាឡេស៊ី ជាក្រុមមកធ្វើការងារសាសនា ស្នាក់នៅខេត្តកំពត បានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យខេត្តកំពត។

ខ. ស្រ្តីអាយុ ៣៥ឆ្នាំ ជនជាតិខ្មែរ រស់នៅខេត្តបាត់ដំបង បានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យខេត្តបាត់ដំបង។ ស្រ្តីរូបនេះ ជាភរិយាបុរសអាយុ ៤៦ឆ្នាំ ដែលបានវិលត្រឡប់មកពីចូលរួមពិធីសាសនានៅប្រទេសម៉ាឡេស៊ី ហើយបុរសរូបនេះ កំពុងព្យាបាលនៅមន្ទីរពេទ្យខេត្តបាត់ដំបងនៅឡើយ។

គ. បុរសអាយុ ៦០ឆ្នាំ ជនជាតិខ្មែរ នៅភូមិបារ៉ែនក្រោម ឃុំស្វាយប្រទាល ស្រុកស្អាង ខេត្តកណ្តាល បានជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យខេត្តកណ្តាល។ បុរសរូបនេះជាក្រុមដែលវិលត្រឡប់មកពីចូលរួមពិធីសាសនានៅប្រទេស ម៉ាឡេស៊ី។



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

ឃ. បុរសជនជាតិខ្មែរអាយុ ៣៩ឆ្នាំ ជាមន្ត្រីជាន់ខ្ពស់នៃក្រសួងមួយ រស់នៅរាជធានីភ្នំពេញ បានជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។

ង. បុរសចំនួន ០៤នាក់ និងស្ត្រីចំនួន ០៤នាក់ ជាជនជាតិបារាំង បានជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តចំនួន ០២លើក។ បុរសស្ត្រីទាំង ០៨នាក់នេះ ជាក្រុមអ្នកទេសចរបារាំង ៣៦នាក់ នៅខេត្តព្រះសីហនុ។ រីឯ បុរសជនជាតិបារាំងអាយុ ៦៨ឆ្នាំ (ជាអ្នកទេសចរក្នុងក្រុមបារាំង ០៨នាក់ផ្សេងទៀត) ក៏បានជាសះស្បើយដែរ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ១៩ ចំនួន ០២លើក។ បុគ្គលទាំង ០៩នាក់នេះ ត្រូវបានអនុញ្ញាតឲ្យចេញពីកន្លែងព្យាបាលនៅក្នុងសណ្ឋាគារមួយនៃក្រុងព្រះសីហនុ ដើម្បីរង់ចាំវិលត្រឡប់ទៅប្រទេសបារាំងវិញ។

ច. បុរសជនជាតិខ្មែរអាយុ ៣៩ឆ្នាំ ជាអ្នកប៉ះពាល់ផ្ទាល់ជាមួយក្រុមទេសចរបារាំង បានជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ១៩ ចំនួន ០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីកន្លែងព្យាបាលនៅក្នុងសណ្ឋាគារមួយនៃក្រុងព្រះសីហនុ។

**៣. មិនមានករណី កូវីដ ១៩ ថ្មី** នៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២០។

ក្រុមការងាររបស់ក្រសួងសុខាភិបាល កំពុងតែធ្វើកិច្ចការស្រាវជ្រាវករណីថ្មីជាបន្តទៀត ហើយនឹងបន្តជម្រាបជូនដល់បងប្អូនសាធារណជន ប្រសិនបើមានរកឃើញករណីវិជ្ជមានវីរុសកូវីដ១៩ ថ្មីណាផ្សេងទៀត។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រ ហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃសៅរ៍ ១២កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០២០

វេជ្ជបណ្ឌិត **ឱ វណ្ណឌីន**

រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យ

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា